រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃព្រហស្បតិ៍ ទី ១៨ ខែ ធ្នូ ឆ្នាំ២០០៨

## របាយការណ៍សំយោគទី ២១ របស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ

## ជាទូទៅលក្ខខណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរនៅតែល្អ ទោះបីជាមានសម្ពាធកើនឡើងពីវិបត្តិហិរញ្ញវត្ថុអន្តរជាតិក៏ដោយ

ភ្នំពេញ ប្រទេសកម្ពុជា_ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) នៅថ្ងៃនេះចេញផ្សាយនូវ "របាយការណ៍សំយោគទី ២១ ស្តីពីលក្ខខណ្ឌការងារនៅក្នុងវិស័យកាត់ដេរកម្ពុជា" ដែលធ្វើការវាយតំលៃលើការអនុលោមទៅតាមច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារអន្តរជាតិនៅក្នុងរោងចក្រកាត់ដេរ។

របាយការណ៍សំយោគទី ២១ នេះ គឺជារបាយការណ៍សំយោគទី៥ ដែលត្រូវចេញផ្សាយតាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានស្វ័យប្រវត្តិ (IMS) ដើម្បីប្រមូល និងរក្សាទុកទិន្នន័យទទួលបានពីការចុះត្រួតពិនិត្យមើលរោងចក្រនិងបង្កើតចេញជារបាយការណ៍។

របាយការណ៍សំយោគនេះមានផ្ទុកព័ត៌មានសំបូរបែបដែលរួមបញ្ចូលការរកឃើញលើគ្រប់ផ្នែកអនុលោមតាមច្បាប់ទាំងអស់ ជាមួយនឹងសិទ្ធិជាមូលដ្ឋាន និងលក្ខខណ្ឌការងារមួយចំនួន ដែលត្រូវបានជ្រើសរើស ។ ទិន្នន័យ ត្រូវបានបង្ហាញក្នុងរូបភាពជាតារាង និងក្រាហ្វិកដែលងាយស្រួលអាន ។

របាយការណ៍សំយោគនេះ បញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាដោយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងការងារ និងក្រសួងពាណិជ្ជកម្ម សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសហជីពដើម្បីធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេរសំលៀកបំពាក់កម្ពុជាដើម្បីឱ្យជំរុញឱ្យមានភាពវិជ្ជមានទៅលើបទដ្ឋានការងារ។

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

ទោះបីជាមានកង្វល់លើបញ្ហាមួយចំនួននៅតែមានជាពិសេសទាក់ទងសេរីភាពក្នុងការបង្កើតអង្គការវិជ្ជាជីវៈ និងការរើសអើងក្តី ក៏បញ្ហាទាំងអស់នេះត្រូវបានធ្វើឱ្យប្រសើរឡើងនាពេលបច្ចុប្បន្ននេះ។

ទស្សនៈសេដ្ឋកិច្ចលើវិស័យកាត់ដេរថ្មីៗនេះ មានផលប៉ះពាល់ដោយការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ហើយឧស្សាហកម្មនេះជួបប្រទះនូវការប្រឈមមុខជាច្រើនដើម្បីរក្សាទីផ្សានិងបន្តរស់រានក្នុងកាលៈទេសៈដែលចំនួនការបញ្ជាទិញផលិតផលមានការថយចុះ។ វិបត្តិហិរញ្ញវត្ថុ ធ្វើឱ្យការនាំចូល ផលិតផលសំលៀកបំពាក់ចូលសហរដ្ឋអាមេរិចធ្លាក់ចុះចំនួន ៣.១%រហូតដល់ខែកញ្ញាឆ្នាំនេះ។

កំឡុងពេលវេទិកាអ្នកបញ្ជាទិញនៅកម្ពុជាថ្មីៗនេះ ដែលបណ្តាអ្នកបញ្ជាទិញធំៗមកជួបប្រជុំគ្នាពិភាក្សាពីកម្មវិធី *រោងចក្រកាន់តែប្រសើរ* និងទស្សនៈវិស័យឧស្សាហកម្មកាត់ដេរ តំណាងម៉ាកផលិតផលទាំងអស់បានបញ្ជាក់ថាពួកគេនៅតែប្តេជ្ញាធ្វើតាមគោលការណ៍ផលិតកម្មដែលមានទំនួលខុសត្រូវ។ នៅក្នុងគំនិតរបស់ពួកគេប្រទេសកម្ពុជា មានគុណសម្បត្តិលើសបណ្តាប្រទេសគូរប្រកួតប្រជែងជាច្រើនក្នុងចំណោមនោះគឺកេរ្តិ៍ឈ្មោះល្បីល្បាញខាងលក្ខខណ្ឌការងារល្អ ប៉ុន្តែប្រទេសកម្ពុជាត្រូវការធ្វើការងារបន្ថែមទៀតលើទំនាក់ទំនងវិជ្ជាជីវៈ អភិបាលកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ។

តំណាងឧស្សាហកម្មកាត់ដេរក៏បានលើកឡើងពីកង្វល់នានារបស់ពួកគេពីចំណាយក្នុងការធ្វើទុរកិច្ច នៅខណៈដែលសហជីព មើលឃើញនូវកំណើនសម្រាប់ការងារប្រញាប់ប្រញាល់ដែលជាមូលហេតុទាមទារឱ្យធ្វើការបន្ថែមម៉ោង ហើយកើតមានឡើងនូវការទទួលម៉ៅការបន្ត។

វាច្បាស់ណាស់ថាអ្នកមានតួនាទីក្នុងវិស័យនេះទាំងអស់ត្រូវយកចិត្តទុកដាក់លើការអំពាវនាវរបស់រដ្ឋាភិបាល ដែលធ្វើឡើងក្នុងវេទិការវាងរដ្ឋាភិបាល និងវិស័យឯកជនលើកទី១៤កាលពីខែវិច្ឆិកា ដើម្បីឱ្យមានកិច្ចសហការគ្នាកាន់តែខ្លាំងឡើងក្នុងគោលបំណងបង្កើនផលិតភាព ហើយរក្សាភាពសុខដុមរមនាក្នុងឧស្សាហកម្មប្រសិនបើឧស្សាហកម្មកាត់ដេរកម្ពុជា អាចមានសង្ឃឹមទ្រាំទ្រនឹងវិបត្តិសេដ្ឋកិច្ចដោយមិនធ្វើឱ្យប៉ះពាល់លើដំណើរការពាណិជ្ជកម្ម ឬកំលាំងពលកម្មចំនួន ៣៥០.០០០នាក់របស់វិស័យឧស្សាហកម្មនាំចេញសំលៀកបំពាក់នេះ។

អង្គការពលកម្មអន្តរជាតិ និងកម្មវិធីគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នឹងបន្តធ្វើការជាមួយដៃគូរទាំងអស់ក្នុងដំណាក់កាលដ៏លំបាកនេះក្នុងការជួយឧស្សាហកម្មដើម្បីរក្សាបានផលចំណេញពីការធ្វើឱ្យប្រសើរឡើងលើលក្ខខណ្ឌការងារក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។ កិច្ចខិតខំបន្ថែមទៀត នឹងធ្វើលើការការពារជម្លោះ កិច្ច

សហការនៅកន្លែងធ្វើការ ក៏ដូចជាការកសាងសមត្ថភាព ហើយក៏ត្រូវធ្វើការផងដែរជាមួយនឹងរដ្ឋាភិបាល អ្នកបញ្ជាទិញ សហជីព និងអ្នកផលិតដើម្បីបង្កើនផលិតភាពឱ្យកាន់តែប្រសើរ និងមានវិធានដ៏សមស្របសម្រាប់សន្សំសំចៃថ្លៃចំណាយ។

របាយការណ៍សំយោគទី ២១ នេះ បង្ហាញនូវតួលេខអនុលោមតាមច្បាប់ ដែលផ្អែកទៅលើទិន្នន័យពិនិត្យឃ្លាំមើល ដែលមាននៅក្នុងរបាយការណ៍រោងចក្រចំនួន ២០៥ ដែលត្រូវបានបំពេញនៅរវាងថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៨ និងថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨ នេះ។

លទ្ធផលដែលបានរកឃើញសំខាន់ៗមួយចំនួន មានដូចតទៅ ÷

- ៨៦% នៃក្នុងរោងចក្រដែលបានត្រួតពិនិត្យមើលមានកម្មករនិយោជិតតិចជាង ២០០០នាក់ ។
- ៦២% នៃកម្មករនិយោជិតធ្វើការងារក្នុងរោងចក្រដែលមានកម្មករនិយោជិតតិចជាង ២០០០នាក់។
- ៧៧% នៃរោងចក្រ ដែលបានត្រួតពិនិត្យមើល មានសហជីពយ៉ាងហោចណាស់មួយ
- រោងចក្រដែលបានត្រួតពិនិត្យមើលមានពាក់ពន្ធ័នឹងការប្រឆាំងការរើសអើងសហជីពតិចជាងរបាយការណ៍សំយោគទី២០។
- រោងចក្រដែលបានត្រួតពិនិត្យមើលចំនួន ១៥% មានកូដកម្ម
- ការអនុលោមទៅតាមលក្ខខណ្ឌប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតពេញសិទ្ធិនៅតែមានកម្រិតខ្ពស់(៩៧%)ចំពោះការអនុលោមទៅតាមការផ្តល់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតម្តងម្កាលបើទោះបីជាកើនឡើង ៧%ក៏ដោយ ក៏នៅតែមានកម្រិតទាបជាងការអនុលោមសម្រាប់កម្មករពេញសិទ្ធិ (៧៧% នៅក្នុងរោងចក្រដែលជួលកម្មករនិយោជិតម្តងម្កាល)
- មានការរីកចំរើនបន្តិចបន្តួចចំពោះការអនុលោមតាមច្បាប់ទាក់ទងនឹងការទូរទាត់លំហែរមាតុភាព (កើនឡើង៨%)លើសរបាយការណ៍មុន ហើយការអនុលោមតាមច្បាប់សម្រាប់ការឈប់សំរាកពេលឈឺ (កើនឡើង១១%) ការអនុលោមតាមច្បាប់សម្រាប់ការទូរទាត់ប្រាក់ខែមានការប្រសើរឡើង ប្ញនៅដដែលគ្រប់ផ្នែកទាំងអស់លើកលែងតែមួយ(អត្រាការងារបន្ថែមម៉ោងត្រឹមត្រូវសម្រាប់កម្មករនិយោជិតស៊ីបុង គឺថយចុះ ៣%)
- មានការរីកចំរើនតិចតួចចំពោះកម្មករនិយោជិត ដែលអនុលោមទៅតាមលក្ខខណ្ឌច្បាប់មុនពេលធ្វើកូដកម្ម ការអនុលោមទៅតាមច្បាប់ស្តីពីការកំណត់ចំនួន និងថេរៈវេលាសម្រាប់ធ្វើការបន្ថែមម៉ោងគឺថយចុះចំនួន ៥% និង១២% ។
- បញ្ហា៣ ក្នុងចំណោមបញ្ហាទាំង១០ ដែលឃើញមានការប្រសើរឡើងបំផុតតាំងពីរបាយការណ៍មុនទាក់ទងនឹងការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ ។

«របាយការណ៍សំយោគ ទី ២១ ស្តីពីលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា» មានជាភាសា **ខ្មែរ** **អង់គ្លេស** និង **ចិន** ដែលអាចយកបានពីវិបសាយ www.betterfactories.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

លោក នី យូ មន្ត្រីទំនាក់ទំនង
អ៊ីម៉ែល: you@ilo.org
ទូរស័ព្ទ: +៨៥៥ ១២ ៣៧៣ ៨៧៧